# យួនត្រូវ«ខ្វាក់»កោះត្រល់ទាំងអាម៉ាស់ !

ដោយ សុទ្ធ-ប៉ូលិន ⋆ ថ្ងៃទី១ មីនា ២០០៦

ក្នុងប្រការធ្វើក្ដីក្ដាំតណ្ដើមទឹកដីពីយួនមកវិញ... យើងត្រូវប្រើឯកសារ ។ បើគ្មានឯកសារទេ ក៏យើងគ្មានទឹកមាត់ឯណា ទៅតវ៉ាជាមួយតុលាការអន្តរជាតិនោះដែរ (ប្រការព្រះវិហារជាមួយសៀមជាឧទាហរណ៍) ។ ការប្រើចំបាំងរាំងជល់ជាដំណោះស្រាយ គឺជាអំពើល្ងង់ខ្លៅ ពីព្រោះកម្លាំងទ័ពរបស់យើងតិចតួចជាងគេ... ចំណែកជម្លោះរវាងខ្មែរនិងខ្មែរ ដោយចោទប្រកាន់អ្នកនេះឬអ្នកនោះកាត់ដីឲ្យយួន នោះក៏ជាការធ្លាក់ចូលក្នុងឧបាយកលរបស់ខ្មាំងយួនដូចគ្នាដែរ... ពីព្រោះយួនត្រូវការឲ្យខ្មែរយើងឈ្លោះគ្នា ដើម្បីបំបាត់ដានឆៃអំពើចោរកម្មប្លន់ទឹកដីរបស់វា ។

យើងត្រូវយកឯកសារបារាំងមកប្រើជាមធ្យោបាយ ដើម្បីទាមទារយកទឹកដីរបស់យើងមកវិញ... ពីព្រោះខ្មែរហើយនិងយួន ធ្លាប់រស់នៅក្រោមអាណានិគមបារាំងដូចគ្នា ។

ឯកសារបារាំងជាផ្លូវការបានសរសេរដូច្នេះថា ៖

«ទឹកដីដែលពួកសៀមបានតណ្ដើមយកទៅ ក៏ត្រូវបង្វិលមកកម្ពុជាវិញ នៅថ្ងៃទី៩ ខែធ្នូ ១៩៤៦ ។ ក៏ប៉ុន្តែទឹកដីដែលយួនបានដណ្ដើមយកទៅ មិនបានត្រូវបង្វិលមកខ្មែរវិញទេ ។ បើទោះជាមានសេចក្ដីសន្យាពីឧត្ដមនាវី De la Grandière យ៉ាងណាក៏ដោយ, រដ្ឋសភាបារាំង, នៅយប់ថ្ងៃទី២១ ឧសភា ១៩៤៩ បានបោះឆ្នោតភ្ជាប់ដែនដីកូសាំងស៊ីន, អតីតទឹកដីអាណានិគម, មិនមែនទភ្ជាប់ឲ្យទៅប្រទេសកម្ពុជា ដែលធ្លាប់មានកម្មសិទ្ធិប្រវត្តិសាស្ត្រទៅលើទឹកដីទាំងនេះទេ, ប៉ុន្តែភ្ជាប់ទៅឲ្យវៀតណាមវិញ ។ ដូច្នេះទៅជនជាតិខ្មែរ ៦០០,០០០នាក់, ដែលរស់នៅដោយសារមុខរបរកសិកម្ម និងជំនួញជួញដូរតូចតាច ក៏បានធ្លាក់ទៅក្រោមនឹមនៃរដ្ឋមួយ (យួន) ដែលប៉ុនប៉ងប្រាថ្នាបំផ្លិចបំផ្លាញភាសានិងទំនៀមទំលាប់ប្រពៃណីពីដូនតារបស់ពួកគេ» ( ដកស្រង់ចេញពី Histoire du Cambodge par A. Dauphin-Meunier - Press Universitaires de France - Paris 1968 - p-114) ។

⋆⋆⋆ ដូច្នេះ ការកាត់ទឹកដីកម្ពុជាក្រោមឲ្យទៅយួន (ដោយមានទឹកដីកោះត្រល់នៅក្នុងនោះដែរ និងដោយមានខ្សែបន្ទាត់ប្រេវីយេ ជាព្រំដែនសមុទ្ររវាងកម្ពុជា-

វៀតណាម) បានប្រព្រឹត្តឡើងជាផ្លូវការ ដោយប្រទេសបារាំងបានសំរេចពីលើក្បា-លខ្មែររួចទៅហើយ តាំងពីឆ្នាំ១៩៤៩ ។ ការដែលគួរឲ្យកត់សម្គាល់នៅក្នុងឯកសារខាងលើ គឺប្រទេសបារាំងបានទទួលស្គាល់ថា ខ្មែរមានកម្មសិទ្ធិជាម្ចាស់ទឹកដីកូសាំងស៊ីន... តែប្រែជាលើកទឹកដីនេះទៅឲ្យវៀតណាមទៅវិញ ។ ប៉ុន្តែទោះជាយ៉ាងនេះក្តី សាធារណរដ្ឋបារាំងមិនបានចង់ឲ្យខ្មែរបាត់បង់ទឹកដីកោះសមុទ្រ ឲ្យលើសពីខ្សែបន្ទាត់ប្រេវីយេនោះឡើយ... ដែលជាមរតកជាផ្លូវការបន្សល់ទុកដោយបារាំងអា-ណានិគម សំរាប់ជាមរតកជាផ្លូវការបន្សល់ទុកដោយបារាំងអាណានិគមសំរាប់ឲ្យខ្មែរ-យួនចែកទឹកដីគ្នា ។

ដូច្នេះ នៅពេលដែលរាជការ«សង្គមរាស្ត្រនិយម»របស់សម្តេចសីហនុ ចាប់ផ្តើមធ្វើការចរចាជាមួយយួនខាងជើង (១៩៦៤) ឲ្យទទួលស្គាល់«ព្រំដែនបច្ចុប្បន្ន»នៃប្រសេទសកម្ពុជា... គឺសំអាងទៅលើព្រំដែនដែលបន្សល់ទុកដោយអាណានិគមបារាំង, បើព្រំដែនសមុទ្រគឺនៅលើខ្សែបន្ទាត់ប្រេវីយេ ។ នៅពេលដែលសាធារណរដ្ឋបារាំងរបស់លោកឧត្តមសេនិយដឺគ្កោលប្រកាសទទួលស្គាល់«ព្រំដែនបច្ចុប្បន្ន»នៃកម្ពុជា... ក៏សំអាងទៅលើខ្សែបន្ទាត់ប្រេវីយេ (១៩៦៦) ។ នៅពេលដែលរដ្ឋការនិចសុំនយល់ព្រមទទួលស្គាល់ «បូរណភាពទឹកដី»នៃប្រទេសកម្ពុជានៅក្នុងឆ្នាំ១៩៦៨... ក៏សំអាងទៅលើខ្សែបន្ទាត់ប្រេវីយេដូចគ្នា ជាព្រំដែនកម្ពុជារវាងប្រទេសកម្ពុជានិងវៀតណាមខាងត្បូង ។

បញ្ហាស្ថិតនៅត្រង់ថា រដ្ឋការវៀតណាមខាងត្បូង ជាបន្តបន្ទាប់ ជាពិសេសគឺរដ្ឋការង៉ោ-ឌិនយៀម និងង្វៀង-យ៉ាំងធីវ មិនដែលព្រមទទួលស្គាល់ខ្សែបន្ទាត់ប្រេវី-យេនោះទេ ។ ពួកគេមិនសប្បាយចិត្ត ត្រឹមតែបានកាន់កាប់កោះត្រល់ប៉ុណ្ណោះទេ... គឺពួកគេចង់វាតយកដីកោះខ្មែរទាំងអស់ ដែលនៅជាប់នឹងឆ្នេរខេត្តកំពត ដែលសំ-បូរដោយរ៉ែលោហធាតុដែក, ថ្មកំបោរ (phosphate de chaux) សំរាប់ធ្វើជីរនិងស៊ី-ម៉ង់ ហើយនិង«មាសខ្មៅ»ជាមហាសាល (ប្រេងកាត) ។

នៅក្នុងសៀវភៅ Histoire du Cambodge ដដែល ទំព័រ១២៣, លោក A. Dauphin-Meunier បានសរសេរថា ៖ «ចំណែករដ្ឋាភិបាលព្រៃនគរវិញ មិនសប្បាយចិត្តនឹងប្រើអំណាចសង្កត់សង្កិនទៅលើជនជាតិខ្មែរ ៦០០,០០០នាក់ នៅដែនដីកូ-សាំងស៊ីនប៉ុណ្ណោះទេ (<u>កកន</u> ៖ ជនជាតិខ្មែរជាប្រជាជនភាគច្រើននៅដែនដីកូសាំងស៊ីន, ម៉្លោះហើយមិនមែនមានតែ៦០០,០០០នាក់ប៉ុណ្ណោះទេ ពេលដែលបារាំងចាកចេញទៅ... លេខចំនួននេះជាទង្វើថ្មិនភ្នែករបស់ពួករដ្ឋការយួនតែប៉ុណ្ណោះ) រដ្ឋការព្រៃនគរថែមទាំងទាមទារជាផ្លូវការ តាំងពីឆ្នាំ១៩៦០ នូវកោះសមុទ្រខ្មែរស្ទើរតែទាំងអស់ ដែលមានទំនាក់ទំនងជាមួយនឹងខេត្តកំពត» ។

⋆⋆⋆ ទៅថ្ងៃមុខទៅ, នៅក្នុងឆ្នាំ១៩៧៣, លោកប្រធានាធិបតីង្វៀង-យ៉ាំងធីវនៃវៀតណាមខាងត្បូង ថែមទាំងបានបញ្ជូនកងម៉ារីនយួន ទៅគំរាមកំហែងក្រុមហ៊ុន

បារាំង Elf-Erap មិនឲ្យរុករកប្រេងកាតនៅកោះសមុទ្រខ្មែរពូឡូវ៉ៃ ។ នៅក្នុងពេលជាមួយគ្នានោះ លោកធីវបានប្រកាសថា ៖ «តទៅអនាគត ប្រទេសកម្ពុជានឹងធ្លាក់ទៅជាប្រទេសចំណុះវៀតណាម, ត្រង់នៅក្រោមវៀតណាមណាមួយ... ខាងជើងឬខាងត្បូង នោះមិនមែនជារឿងសំខាន់ទេ» ។ (កំណាត់របស់លី-ឡៀប ៖ កាលពីឆ្នាំ២០០៩ ខ្ញុំបានចុះផ្សាយនូវឯកសារយ៉ាងសំខាន់មួយ ស្ដីអំពីការប្រជុំរបស់ពួកយួនសេរី នៅទីក្រុងសាន់តា-អាណា រដ្ឋកាលីហ្វ័រនិញ៉ា ក្រោមអធិបតីភាពរបស់លោកង្វៀង-កៅគី ដែលទើបវិលត្រឡប់ពីទស្សនកិច្ចនៅទីក្រុងហាណូយ ។ លោកង្វៀង-កៅគី បច្ចុប្បន្នមេដឹកនាំរដ្ឋាភិបាលក្រៅស្រុកយួនសេរីក្រុមទី២ (ក្រុមទី១ដឹកនាំដោយលោកង្វៀង-ខាន់) បាននិយាយប្រាប់ទៅពួកអ្នកគាំទ្រខ្លួនថា សូមឲ្យពួកយួនសេរីបង្អន់ដៃ ឈប់ឆារឆៅពួករដ្ឋាភិបាលបច្ចុប្បន្ន ពីព្រោះពួកគេកំពុងមានឥទ្ធិពលកាន់ក្ដាប់លើស្រុកខ្មែរទាំងមូល ហើយនិងទុកឱកាសឲ្យពួកគេធ្វើកិច្ចការជាផលប្រយោជន៍ដល់ជាតិវៀតណាមទាំងមូល ។ «ពួកខ្មែរវាគ្មានដឹងអីទេ គឺដូចជាត្រីពុលអញ្ចឹង កំពុងសប្បាយភ្លេចខ្លួន និងកំពុងខាំគ្នាវក់វី», លោកង្វៀង-កៅគីនិយាយប្រាប់អង្គប្រជុំនៅក្នុងភោជនីយដ្ឋានមួយ ដែលកិច្ចប្រជុំនេះមានរយៈពេលជិតភ្លឺ ។ នៅរាល់ពេលខ្ញុំនឹកដល់សំដីរបស់លោកង្វៀង-កៅគីនេះ ខ្ញុំមានការឈឺចាប់ក្នុងចិត្តខ្លាំងណាស់ ជាពិសេសក្រោយពេលខ្ញុំបានក្រឡេកឃើញពួកមេៗខ្មែរ (រួមទាំងស្ដេចផង) បាននាំគ្នាទាំងហ្វូងទាំងហ្វាយ ទៅផ្គាប់ផ្គុនយកចិត្តយួន ។ ការធ្វើសន្ធិសញ្ញាបំពេញបន្ថែម គឺជាទង្វើដ៏ឆោតល្ងង់ក្រៃលែងនៃថ្នាក់ដឹកនាំខ្មែរ (លោកហ៊ុន-សែនរហូតដល់ទៅកណ្ដៀតតាមខ្លួន យកសន្ធិសញ្ញាដែលខ្លួនលបធ្វើនោះ ទៅស៊ីញ៉េដល់ផ្ទះចៅហ្វាយឯក្រុងហាណូយទៅទៀត) រួចហើយថែមពីលើនេះ បានទាំងប្រព្រឹត្តនូវអំពើថោកទាបព្រៃផ្សៃ ដោយបានធ្វើការឃ្លុំមាត់ ចាប់អ្នកជាតិនិយមជាខ្មែរគ្នាឯងយកទៅញាត់គុកច្រវាក់ ។ នេះហើយឬ ការវង្វេងរបស់ខ្មែរយើង ?!) ។

គិតទៅង្វៀង-យ៉ាំងធីវមានបុកពារព្រហើនកោងកាច ប្រហែលគ្នានឹង ផាំ-យ៉ាំងដុង (អាកុងដូចអាកា) ។ ជនទាំងពីរនេះ មិនមែនត្រឹមតែចង់បានកោះត្រល់ឬកោះសេះ ឬក៏អាណាខេត្តកំពតតែប៉ុណ្ណោះទេ... ពួកវាមានគោលប្រាថ្នាលើទឹកដីកម្ពុជាទាំងមូល ។

⋆⋆⋆ ចុះហេតុយ៉ាងដូចម្ដេច បានជានៅក្នុងពេលបច្ចុប្បន្ន ដែលចូលហួសសតវត្សទី២០ទៅហើយ ពោលគឺចូលដល់ឆ្នាំ២០០៦ទៅហើយ... កម្ពុជាកណ្ដាលរបស់យើង មិនឃើញបាត់បង់ទៅណាទៅ ? ។ ផាំ-យ៉ាំងដុងបានលេបទឹកដីកម្ពុជាទាំងមូល នៅក្នុងឆ្នាំ១៩៧៩... ហេតុអ្វីបានជាវាមិនលេបរហូតទៅ ? ។ ហេតុអ្វីបានជាយួនត្រូវខ្ជាក់ទឹកដីខ្មែរកណ្ដាលមកវិញ កាលក្នុងឆ្នាំ១៩៨៧ ដោយដកកងទ័ពរបស់វាត្រឡប់ទៅវៀតណាមវិញ ? ។ ប្រការទាំងនេះ គឺមកពីវាលេបមិនរួច វាត្រូវតែខ្ជាក់មកវិញដូច្នេះឯង !! ។ ពីថ្ងៃនេះតទៅ... យួនមានតែខ្ជាក់ប៉ុណ្ណោះ... ឥតមានលេ

បបានសាជាថ្មីទេ ។ កាលណាគេជ្រុលជាខ្ទាក់ទៅហើយ គេត្រូវតែខ្ទាក់ទាំងអស់ ។ មុខមាត់របស់ផាំ-យ៉ាំងជុំង មុនពេលស្លាប់ ជាមុខមាត់អភ័ព្វនៃជនបរាជ័យ ដែលត្រូវបង្ខិលទ្រព្យសម្បត្តិដែលខ្លួនប្លន់គេឲ្យទៅគេវិញ ! ។

★★★ ចុះនៅក្នុងពេលសព្វថ្ងៃនេះ, យួនមានកោះត្រល់នៅក្នុងមាត់របស់វាទៅហើយ ម្ដេចក៏វាមិនលេបយកទៅ ? ហ៊ុន-សែនជាអាយ៉ងរបស់យួនស្រាប់ ព្រមទាំងមានអំណាចច្រើនជាងស្ដេចទៅទៀត... ចុះម្ដេចបានជាចាំបាច់ឆ្កៀមឆ្កួមធ្វើសន្ធិសញ្ញាបន្ថែម «កុំឲ្យខ្មែរថាជារបស់ខ្មែរ ចំណែកយួនថាជារបស់យួន» យោងតាមសំដីផ្ទាល់របស់ហេង-សំរិន ??

សព្វថ្ងៃនេះគេអាចមើលឃើញសញ្ញាច្បាស់ណាស់ ថាយួនកំពុងហារខ្ទាក់កោះត្រល់មកវិញ ។ បើតាមតែយួនស្រឡាញ់កោះត្រល់ វាសុខចិត្តឲ្យកោះនេះរលាយសាបសូន្យ លិចលង់ទៅបាតសមុទ្រតែម្ដង ជាជាងបង្ខិលត្រឡប់ឲ្យខ្មែរវិញ... ចុះហេតុអ្វីបានជាយួនអនុញ្ញាតឲ្យខ្មែរនៅភ្នំពេញដាក់វិនិយោគទុន សាងសង់វិមានវិស្សមកាលនៅកោះត្រល់ ? ខ្មែរជាជនល្ងង់ខ្លៅពិតមែន... ប៉ុន្តែ«លុយរកស៊ី»វាងវៃឆ្លាតណាស់... វាមិនត្បូលទៅរស់នៅកន្លែងណាដែលវាគ្មានអនាគតនោះទេ ។ ប៉ុន្តែសូមប្រយ័ត្នណា៎ ! កោះត្រល់ជាប់នឹងដែនដីខេត្តកំពតពិតមែន... ប៉ុន្តែកោះនេះជានិមិត្តរូបនៃដែនដីកម្ពុជាក្រោម ដោយត្រូវយួនប្លន់យកទៅចំនួន២៩១ឆ្នាំមកហើយ ជាមួយនឹងខេត្តពាម (ហាទៀង) ។ កាលណាយួនខ្ទាក់កោះត្រល់... គឺយួនកំពុងខ្ទាក់ទឹកដីកម្ពុជាក្រោមទាំងមូលមកឲ្យខ្មែរវិញ !

ដើម្បីចង់ដឹងថា តើហេតុអ្វីយួនមានកាតព្វកិច្ចចាំបាច់ត្រូវតែខ្ទាក់កោះមកវិញ... យើងត្រូវសិក្សាវិភាគអំពីឯកសារប្រេវីយេ ។

❑

❑ ❑

# ប្រវត្តិនៃខ្សែបន្ទាត់ប្រេវីយេ

នៅក្នុងសម័យអាណានិគមបារាំង ការចាប់ផ្ដើមដណ្ដើមកោះសមុទ្រនៅជាប់នឹងខេត្តកំពត រវាងខ្មែរ-យួន បានប្រព្រឹត្តទៀងតាំងពីឆ្នាំ១៩១៣ (មកទល់ឥឡូវនេះគឺជិតមួយសតវត្សហើយ) ។ តាមពិតគឺជាការដណ្ដើមគ្នារវាងរដ្ឋការបារាំងនៅកូសាំងស៊ីន ហើយនិងរដ្ឋការបារាំងប្រចាំនៅប្រទេសកម្ពុជា ។ គួរកត់សម្គាល់ថា ពួកគេមិនបានដណ្ដើមគ្នាអំពីកោះត្រល់ទេ... ដោយបារាំងទាំងសង្ខាងបានទុកកោះត្រល់នៅខាងយួនទៅហើយ (ដូច្នេះខ្សែបន្ទាត់ប្រេវីយេបានធ្វើឡើង ដោយមិនពាក់ព័ន្ធនឹងកោះត្រល់ទេ... ដែលបារាំងទុកដោយឡែកជាបណ្ដោះអាសន្ន ជាកម្មសិទ្ធិនៃដែនដីកូសាំងស៊ីន សំរាប់សំរួលកិច្ចការរដ្ឋបាលនិងក្រសួងប៉ូលិស)... ប៉ុន្តែកិច្ចការដណ្ដើមកោះនេះ គឺសំដៅទៅលើកោះផ្សេងៗឯទៀតទាំងអស់ លើកលែងតែកោះ

ត្រល់ ។ (កកន ៖ សូមមើលផែនទីភ្ជាប់មកជាមួយ នៅខាងចុងអត្ថបទ) ។

«បញ្ហាបានចាប់ផ្តើមឡើង ដោយមានការដាក់ពាក្យសុំបាំតង់កាន់កាប់ដីនៃកោះទាំងនេះ ដែលសំបូរដោយរ៉ែថ្មកំបោរ និងលោហធាតុដែក ។ មិនដល់មួយខែផង អភិបាលនៅហាទៀង បានទទួលសំបុត្រដាក់ពាក្យសុំចែកឡូត៍អណ្តូងរ៉ែចំនួន១៤ កន្លែង ដែលទាក់ទងនឹងកោះក្នុងឈូងសមុទ្រតែប៉ុណ្ណោះ ។

«ចំណែកលោកអភិបាលបារាំងនៅខេត្តកំពតវិញ បានទទួលពាក្យសុំចែកឡូត៍ដីមួយ ដែលស្ថិតនៅកោះតាង» ។

«ម៉្លោះហើយគឺជាការចាំបាច់ ដែលអាជ្ញាធរនៃប្រទេសទាំងពីរត្រូវសំរេចថា តើទឹកដីកោះទាំងនេះ ជាកម្មសិទ្ធិរបស់ទឹកដីខាងណា» (ដកស្រង់ចេញពីសៀវភៅ Les Frontière du Cambodge par Sarin Chhak p.154) ។

★★★ នរណាក៏ដឹងដែរថា អាជ្ញាធរបារាំងនៅខាងយួនមានបុណ្យស័ក្តិធំជាងបារាំងនៅខាងខ្មែរ... ហើយនៅក្នុងប្រការចែកកោះទាំងនេះ នៅក្នុងសហភាពបារាំងសែសតែមួយ គេមិនបានប្រើច្បាប់អន្តរជាតិឯណាទេ, ចុះហេតុដូចម្តេចបានជាទេសាភិបាលបារាំងប្រចាំនៅទីក្រុងហាណូយ មិនបានប្រមូលកោះទាំងអស់នេះប្រគល់ទៅឲ្យខាងយួនទៅ ? តើមាននរណាឃាំងឃាត់ ??

ប្រការនេះ គឺបណ្តាលមកពីអព្ភូតហេតុដ៏ជាក់ស្តែងមួយខាងផ្នែកបរិដ្ឋានភូមិសាស្ត្រ ដែលបានធ្វើឲ្យបារាំងនៅខាងយួន មានសេចក្តីភ័ន្តភាំងស្រឡាំងកាំងអស់រយៈពេល២៦ឆ្នាំ (បីឆ្នាំ១៩១៣ ទៅ១៩៣៩) ពោលគឺមានដីជ្រោយវែងអន្លាយកំពុងតែដុះ ហើយដែលថ្ងៃណាមួយ អាចបន្តភ្ជាប់កោះត្រល់ទៅនឹងតំបន់រាម (បើគេពិនិត្យមើលនៅលើផែនទីសព្វថ្ងៃ ដែលគេអាចទិញបាននៅផ្សារបាយ័ន (ក្រុងឡុងប៊ិច) កោះត្រល់ស្ថិតនៅចម្ងាយប្រមាណ៤ គ.ម.ប៉ុណ្ណោះពីកោះសេះ (សម័យប្រេវីយេហៅថាកោះទឹក) ចំណែកកោះសេះមានចម្ងាយតែ២គ.ម.ប៉ុណ្ណោះពីកោះថ្មី (ក្នុងសម័យប្រេវីយេហៅថា




កោះកណ្តាល)... ចំណែកពីកោះថ្មីទៅតំបន់រាមមានតែចម្ងាយតែ១គ.ម.ប៉ុណ្ណោះមកដល់សព្វថ្ងៃប្រហែលជាដុះជាប់គ្នាទៅហើយ ។ នៅចុងជន្លួញមួយទៀតផ្នែកខាងជើង កោះត្រល់ឋិតនៅចម្ងាយ១២គ.ម.ពីខេត្តកំពត... ចំណែកកន្ទុយកោះ

ត្រល់ ដែលឋិតនៅខាងត្បូងបំផុត មានចម្ងាយ៥០គ.ម.ពីខេត្តហាទៀង ។ ដូច្នេះរដ្ឋការយួនត្រូវដួលដេកស្លាប់ដូចនាងកង្រីនៅត្រើយហាទៀងនោះហើយ... ព្រោះខំហែលទឹកយ៉ាងណា ក៏តាមឫទ្ធិសែនមិនទាន់នៅកោះត្រល់នោះដែរ ! ។

នៅក្នុងសៀវភៅ «ព្រំដែននៃប្រទេសកម្ពុជា» របស់លោកសារិន-ឆាកដដែល នៅទំព័រ១៥៧ មានសេចក្ដីរាយការណ៍របស់នាយកក្រសួងសុរិយោដីនៅភ្នំពេញ ដែលជាជាតិបារាំង ផ្ញើជូនលោករ៉េស៊ីដង់ ស៊ូប៉េរីយើរ កាលពីថ្ងៃទី៩ មករា ១៩១៤ ដែលមានសេចក្ដីដកស្រង់ដូច្នេះថា ៖

«ស្ថានភាពភូមិសាស្ត្រនៃកោះទាំងនេះ ត្រូវចងភ្ជាប់ជាច្បាប់ធម្មជាតិទៅប្រទេ-សកម្ពុជា ដែលនៅទីនោះ គេអាចឃ្លាំមើល (សន្តិសុខ) កោះទាំងនេះយ៉ាងងាយស្រួលជាទីបំផុត ព្រោះជាកន្លែងដែលស្ថិតនៅមិនឆ្ងាយពីក្រុមអាជ្ញាធរខ្មែរ ។

«នៅទីបំផុត ហើយរឿងនេះពុំមែនជារឿងតូចតាចទេ គឺនៅឆកទឹកសាប (នៅជាប់នឹងឆកវាលរេញ) មានដីដុះជារៀងរាល់ឆ្នាំ ធ្វើពីដីល្បប់ ដែលនាំមកដោយព្រែកដែលមានឈ្មោះថាទឹកសាបដូចគ្នា ។ ថ្ងៃមួយខ្ញុំបានដើរឆ្លងកាត់ទឹកនៅម្ដុំនោះ នៅពេលទឹកនាច បន្ទាប់ពីមានគ្រោះថ្នាក់នាវា... ទឹកមានជំរៅ១ម១០តែប៉ុណ្ណោះ គឺនៅពីលើខ្សែក្រវាត់តែបន្តិចបន្តួច ។ ម៉្លោះហើយគឺជារឿងមួយដ៏ចម្លែកខ្លាំងណាស់ ប្រសិនបើថ្ងៃណាមួយ កោះកណ្ដាល (កោះថ្មី) ត្រូវបន្តភ្ជាប់និងទឹកដីកម្ពុជា ដោយសារដីដុះ ហើយមានឈ្មោះប្រែត្រឡប់ថា ជាទឹកដីកូសាំងស៊ីនទៅវិញនោះ នៅពេ-លដែលស្ថានភាពភូមិសាស្ត្រ, ខ្ញុំសូមនិយាយម្ដងទៀតទៅចុះ តាំងពីការកទឹកកដី ជាពិសេសតាំងអំពីដើមកំណើកនៃកោះទាំងនេះតែម្ដង ហើយថ្វីបើមានការរឹបអូស ពីរដ្ឋការកូសាំងស៊ីនយ៉ាងណាក៏ដោយ គឺមានន័យថា តំបន់ទាំងនេះមានដំណើរភិនភាគលក្ខណៈ ដែលត្រូវចងភ្ជាប់ដោយធម្មជាតិ ជាមួយនឹងបូរណភាពទឹកដីនៃប្រទេសកម្ពុជា» ។

(<u>កកន</u> ៖ នៅក្នុងប្រការច្បាប់អន្តរជាតិសព្វថ្ងៃ កោះសមុទ្រដែលនៅចម្ងាយ២០ម៉ែល៍ពីប្រទេសណាមួយ ត្រូវគេចាត់ទុកថា ជាសម្បត្តិទ្រព្យនៃប្រទេសនោះ ។ ដូច្នេះទោះជាមានខ្សែបន្ទាត់ប្រេវីយេក៏ដោយ ឬពុំមានប្រេវីយេក៏ដោយ កោះត្រល់គឺជាទ្រព្យសម្បត្តិនៃប្រទេសកម្ពុជា... ហើយបើយួនមិនគោរពច្បាប់ប្រេវីយេ៉ ក៏វាត្រូវតែគោរពច្បាប់អន្តរជាតិផងដែរ ពីព្រោះប្រទេសនេះមិនអាចរស់នៅតែម្នាក់ឯងបានទេ !) ។

⋆⋆⋆ បន្ទាប់ពីមានរបាយការណ៍នៃក្រសួងសុរិយោដីខាងលើ អស់ចំនួន២៥ឆ្នាំ ទើបបានលោកប្រេវីយេ៉ ទេសាភិបាលឥណ្ឌូចិនបារាំងសែស ប្រចាំនៅទីក្រុងហា-ណូយ ធ្វើសេចក្ដីសំរេចទាក់ទងនិងកោះខ្មែរទាំងអស់នៅជាប់នឹងឆ្នេរកំពត ។ នៅពេលនោះ គឺលោកអគ្គទេសាភិបាលបារាំង ប្រេវីយេ ទាល់តម្រិះអស់សង្ឃឹមក្នុងប្រការយ៉ាងណា យកកោះខ្មែរទាំងអស់ជាប់នឹងឆ្នេរខេត្តកំពត ដោយរាប់តាំងកោះត្រល់មួយផងដែរ យកទៅប្រគល់ឲ្យយួនជាផ្លូវការ ។

លិខិតនៃអគ្គទេសាភិបាល ចុះថ្ងៃ៣១ មករា ១៩៣៩ ទីចំណាត់ការនៃកិច្ចការសាធារណៈ: No 867-API

(កកន ៖ លិខិតនេះបានចុះផ្សាយទាំងស្រុងនៅក្នុងសៀវភៅ «ព្រំប្រទល់នៃប្រទេសកម្ពុជា» ដដែលនៅទំព័រ២០៧)

កម្មវត្ថុ ៖ កោះទាំងឡាយក្នុងឈូងសមុទ្រសៀម

ទីក្រុងហាណូយ, ថ្ងៃទី៣១ មករា ១៩៣៩

អគ្គទេសាភិបាលនៃឥណ្ឌូចិន

Grand Officier de la Légion d'Honneur

ជំរាបមកទេសាភិបាលកូសាំងស៊ីន នៅទីក្រុងព្រៃនគរ

«ខ្ញុំមានកិត្តិយសនឹងបញ្ជូនពត៌មានឲ្យលោកបានជ្រាបថា ខ្ញុំទើបនឹងបានពិនិត្យសើរើឡើងវិញ អំពីបញ្ហានៃកោះទាំងឡាយនៅក្នុងឈូងសមុទ្រសៀម ហើយដែលកម្មសិទ្ធិកាន់កាប់ត្រួតត្រាត្រូវបានប្រជែងដណ្តើមគ្នា រវាងប្រទេសកម្ពុជានិងរដ្ឋការកូសាំងស៊ីន ។

«សភាពការណ៍ហ្វូងកោះទាំងនេះ ដែលស្ថិតនៅរាយប៉ាយ នៅតាមបណ្តោយជួរនៃឆ្នេរសមុទ្រខ្មែរ ហើយដែលមានកោះខ្លះ ស្ថិតនៅប្រឫបជាប់នឹងត្រើយប្រទេសខ្មែរតែម្តង រហូតដល់មានដីដុះរាំងគោក ដែលកំពុងតែប្រព្រឹត្តទៅក្នុងពេលសព្វថ្ងៃ ហើយដែលតម្រូវឲ្យកោះទាំងនេះ តភ្ជាប់ទៅនឹងត្រើយនៃប្រទេសកម្ពុជាតែម្តងក្នុងអនាគតដ៏ខ្លី គឺប្រទាញឲ្យមានលក្ខណៈចាំបាច់ដ៏សមរម្យ យោងតាមសភាពការភូមិសាស្ត្រ ដែលតម្រូវឲ្យកោះទាំងនេះ មានការពឹងពាក់ទៅលើរដ្ឋការនៃប្រទេសចុងក្រោយនេះ (កម្ពុជា) ។

«ខ្ញុំមានយោបល់ថា មិនអាចបន្តសភាពការណ៍សព្វថ្ងៃ ដែលចំរុញឲ្យប្រជាជនដែលរស់នៅលើកោះទាំងនេះ ឲ្យធ្វើដំណើរវែងឆ្ងាយ ដោយវាងតាមជួរទឹកដីខ្មែរដើម្បីទៅធ្វើការទាក់ទងជាមួយនឹងរដ្ឋការកូសាំងស៊ីននោះទៀតទេ ។

«ក្នុងប្រការនេះ ខ្ញុំបានសំរេចថា កោះទាំងឡាយដែលស្ថិតនៅខាងជើងខ្សែបន្ទាត់មួយ ដែលចាកចេញពីមុខត្រង់ (Ligne penpendiculaire) ដែលចាកចេញពីព្រំដែនកម្ពុជា-កូសាំងស៊ីន ហើយបង្កើតជាមុម១៤០អង្សារ ជាមួយនិងខ្សែទិសព្រញខាងជើង (Le Nord du Méridien) ស្របតាមផែនទីដែលភ្ជាប់មកជាមួយនេះ... (កកន ៖ សូមសិក្សាអំពីផែនទីនៃខ្សែបន្ទាត់ប្រេវីយេ ដែលមានបោះពុម្ពផ្សាយនៅក្នុងសៀវភៅ «ព្រំប្រទល់នៃប្រទេសកម្ពុជា» ដដែលនៅពីរទំព័រចុងក្រោយបំផុតដែលមានចំណងជើងថា ព្រំដែនកម្ពុជា-កូសាំងស៊ីន - ស្របតាមកំណត់លេខ 867-API ចុះថ្ងៃ៣១-១-៣៩ របស់អគ្គទេសាភិបាល... ខ្នាតបង្រួម ១/៥០០,០០០) ។ ខ្ញុំសំរេចថា កោះទាំងឡាយដែលស្ថិតនៅខាងជើងនៃខ្សែបន្ទាត់នេះ គឺត្រូវកាន់កាប់ដោយក្រសួងរដ្ឋការនៃប្រទេសកម្ពុជា ។ រដ្ឋបាលនៃប្រូតិចតូរ៉ា (ក្រសួងរដ្ឋការបា

រាំងប្រចាំនៅប្រទេសកម្ពុជា) ជាពិសេសក្រសួងប៉ូលិស ត្រូវទទួលមើលខុសត្រូវទៅលើកោះទាំងនេះ ។

(កកន ៖ យោងតាមសេចក្តីខាងលើនេះ ខ្សែបន្ទាត់ប្រេវីយេឥតមានពីរទេ គឺមានតែមួយ ។ គឺជាខ្សែបន្ទាត់ដែលបង្កើតជាមុមត្រង់ ជាមួយនឹងខ្សែព្រំដែនកែបហាទៀង ហើយដែលចាកចេញត្រង់ភ្លឹង ឆ្ពោះទៅកណ្តាលសមុទ្រ ។ បើយើងយល់ថា អត្ថបទរបស់លោកប្រេវីយេមិនច្បាស់លាស់ តែផែនទីរបស់គាត់ច្បាស់លាស់ណាស់, ខ្សែបន្ទាត់ប្រេវីយេ ជាខ្សែបន្ទាត់ត្រង់ភ្លឹង ឥតមានបត់បែនទេ... គឺបានសេចក្តីថា ខ្សែបន្ទាត់បត់បែនដែលយើងឃើញសព្វថ្ងៃ ជាទង្វើរបស់យួន ។ <u>ខ្សែបន្ទាត់ប្រេវីយេ គឺចែកទឹកដីកោះត្រល់មកឲ្យខ្មែរ</u> ចំណែកខ្សែបន្ទាត់របស់យួន ត្រូវវាងឬកុងកោះត្រល់ផ្នែកខាងជើង... ដើម្បីកេរយកកោះត្រល់ យកមកឲ្យខាងយួនវិញ ។ នេះគឺជាការលួចប្លន់ទាំងកណ្តាលថ្ងៃត្រង់ ពីសំណាក់ជនជាតិយួន ។ ប៉ុន្តែតើមានអន្តរជាតិឯណាសុខចិត្តទទួលស្គាល់ ខ្សែបន្ទាត់មួយដែលបង្កើតជាមុមត្រង់ (Une ligne perpendiculaire) ហើយដែលចេះបត់បែនតាមទំនើងចិត្តនោះ ?) ។

លោកអគ្គទេសាភិបាល ប្រេវីយេ ក៏បានសរសេរលិខិតជាបន្តមកទៀតថា ៖

«កោះទាំងឡាយ ដែលស្ថិតនៅខាងត្បូងនៃខ្សែបន្ទាត់ ដោយរាប់ទៅកោះភូកុកទាំងមូលផង (កោះត្រល់) គឺនៅបន្តទទួលចំណាត់ការពីរដ្ឋបាលកូសាំងស៊ីន ។ គេត្រូវតែយល់ថា ខ្សែបន្ទាត់ព្រំដែន ដែលទើបតែរៀបចំបែបខាងក្រោយនេះ ត្រូវវាងកោះភូកុកផ្នែកខាងជើង ចម្ងាយ៣គ.ម.ពីជ្រុងចុងជ្រោយបំផុតនៃកោះនេះ» ។

(កកន ៖ ត្រង់កន្លែងនេះលោកប្រេវីយេបានសរសេរញ៉ាំត្រណោតពិតមែន ពីព្រោះលោកមិនទាន់ដាច់ចិត្តប្រគល់កោះត្រល់នេះមកឲ្យខ្មែរវិញភ្លាម ដោយហេតុថាពេលដែលលោកឧត្តមនាវី De la Grandière បានទទួលកោះត្រល់ពីដៃយួន គឺបានទទួលជាមួយគ្នានិងខេត្តពាម ហើយនិងខេត្តដទៃទៀតនៃដែនដីកម្ពុជាក្រោម ។ ដូច្នេះកោះត្រល់ជានិមិត្តរូបនៃកម្ពុជាក្រោមទាំងមូល បើបារាំងសំរេចចិត្តឲ្យកោះត្រល់មកកម្ពុជាវិញនៅពេលនោះ កោះត្រល់នឹងក្លាយទៅជាទំពក់សំរាប់ទាក់ទាញយកខេត្តដីក្រោមទាំងអស់ ឲ្យវិលត្រឡប់មកកម្ពុជាកណ្តាល ។ ប៉ុន្តែលោកប្រេវីយេបានបញ្ជាក់ផងដែរថា ខ្សែព្រំដែនទាំងពីរនេះ មួយជាខ្សែបន្ទាត់ត្រង់ មួយទៀតបត់បែនជុំវិញផ្នែកខាងជើងនៃកោះត្រល់ គឺជាខ្សែបែងចែកបណ្តោះអាសន្ន សំរាប់សំរួលកិច្ចការប៉ូលិសតែប៉ុណ្ណោះ ។ ពោលខ្សែព្រំដែនទាំងពីរមិនត្រូវយកជាការរៀងរហូតបានឡើយ សំរាប់ចែកកូសាំងស៊ីន) ។

ជាបន្តមកទៀតលោកប្រេវីយេបានសរសេរថា ៖ « អំណាចរដ្ឋបាលនិងក្រសួងប៉ូលិសនៅលើកោះទាំងអស់នេះ នឹងត្រូវបែងចែកយ៉ាងច្បាស់លាស់ រវាងកូសាំងស៊ីននិងកម្ពុជា ដើម្បីចៀសវាងការតវ៉ាគ្នាទៅអនាគត ។

(កកន ៖ ខ្សែបន្ទាត់ប្រេវីយេមានពីរដូច្នេះ តើគេចៀសវាងម្តេចនឹងកើតទៅ ?) ។

«គេត្រូវយល់ផងដែរថា ចំណាត់ការនេះធ្វើឡើងសំរាប់តែរដ្ឋបាលនិងក្រសួងប៉ូលិស ចំណែកបញ្ហានៃកម្មសិទ្ធិទឹកដី ត្រូវលើកព្យួរទៅថ្ងៃក្រោយទាំងស្រុង ។

«សូមលោកមេត្តារៀបចំយ៉ាងណា ឲ្យសេចក្តីសំរេចរបស់ខ្ញុំទទួលការអនុវត្តន៍ភ្លាមមួយរំពេជ ។

«សូមលោកបញ្ជូនដំណឹងមកខ្ញុំវិញផង ថាបានទទួលសំបុត្រនេះ ។

ហត្ថលេខា ៖ ប្រេវីយេ

★★★ នៅទីបំផុតទៅ... លោកប្រេវីយេបានបញ្ជាក់អះអាងថា ខ្សែបន្ទាត់ប្រេវីយេ មិនមែនជាគំនូសព្រំដែនបែងចែកទឹកដីឡើយ ម៉្លោះហើយការបែងចែកទឹកដីរវាងខ្មែរ-យួន ត្រូវគិតសើរើឡើងវិញទាំងអស់ទៅថ្ងៃក្រោយ ។

យើងមានចម្លល់ថា បើការចែកក្រសួងគ្រប់គ្រងរដ្ឋបាល ហើយនិងក្រសួងប៉ូលិស ពុំមែនជាការចែកទឹកដីទេនោះ តើជាអ្វីទៅវិញ ? ទោះជាយ៉ាងណាក្តី ក្នុងប្រការសើរើឡើងវិញទាំងអស់អំពីខ្សែបន្ទាត់ប្រេវីយេ យួនត្រូវប្រឈមមុខបរាជ័យពីរយ៉ាង ៖

ទី១- យួនត្រូវជ្រើសរើសខ្សែបន្ទាត់ប្រេវីយេ ដែលជាខ្សែបន្ទាត់ត្រង់ បើពុំនោះសោតទេ ឥតមានអន្តរជាតិឯណាទទួលស្គាល់ចុះចូលរកស៊ីជាមួយយួនទេ ។ នៅក្នុងពេលសព្វថ្ងៃនេះ យួនត្រូវការអនុលោមជាមួយអន្តរជាតិ ជាពិសេសប្រទេសយួនដ៏ក្រីក្រ ត្រូវការយ៉ាងរបៀបដាច់ដាបបំផុត នូវប្រាក់វិនិយោគទុនមកពីប្រទេសធំៗមានអឺរ៉ុប, កាណាដា, ជប៉ុន, សហរដ្ឋអាមេរិក ។ ក្នុងប្រការនេះ យួនត្រូវពុះចែក៣/៤ ឬ៤/៥នៃកោះត្រល់មកខ្មែរវិញ ដើម្បីឲ្យខ្សែបន្ទាត់ប្រេវីយេមានតម្លៃជាប្រវត្តិសាស្ត្រ

ទី២- ឬមួយយួនត្រូវទទួលស្គាល់ច្បាប់អន្តរជាតិ ដែលចែងថា កោះសមុទ្រដែលនៅចម្ងាយ២០ម៉ែល៍ពីប្រទេសណាមួយ ត្រូវចាត់ទុកជាកម្មសិទ្ធិនៃប្រទេសនោះ ។ នៅក្នុងប្រការចុងក្រោយនេះ... យួនត្រូវបាត់បង់ទឹកដីកោះត្រល់ទាំងមូល... ចំណែកការលាតសន្ធឹងផ្ទៃទឹកចំនួន២០ម៉ែល៍ ដែលនៅជុំវិញកោះត្រល់ ត្រូវចាត់ទុកថាជាផែនសមុទ្ររបស់ខ្មែរ ។៚

❑ ❑

❑